## *ពិធី និងទិដ្ឋភាព គជលក្ស្មី ក្នុងសិល្បៈខ្មែរ*

*ក្នុងសិល្បៈឥណ្ឌា ព្រះនាងស្រីលក្ស្មីមានទម្រង់៨យ៉ាង* (Asthalaksmi) *ហើយជាទេពដែលមានប្រជាប្រិយភាព ត្រូវបានគេស្គាល់ថាជាទេពនៃសម្ពស្ស និងទ្រព្យសម្បត្តិ។ ចម្លាក់ដែលចាស់ជាងគេក្នុងសិល្បៈឥណ្ឌា គឺបង្ហាញព្រះនាងលក្ស្មីជា* ***គជលក្ស្មី*** *ដែលជាទេពមានសម្រស់យ៉ាងស្រស់ស្អាត អង្គុយនៅចន្លោះដំរី២ក្បាល។ ទាំងព្រះនាងលក្ស្មី និងដំរីទាំង២ គឺតំណាងឱ្យកំលាំង ភាពរុងរឿង និងការអត់ធន់ ដែលទាំងអស់នេះគឺជាភាពថ្លៃថ្នូរក្នុងជិវិត។ ក្នុងទម្រង់បែបនេះ ព្រះនាងអង្គុយនៅលើផ្កាឈូកក្នុងឥរិយាបថ* ***យោគបាទមសន*** (Padmasana Yogi) *មានដៃ៤ ដែលដៃខាងលើទាំង២កាន់ផ្កាឈូក និងដៃខាងក្រោមមានកាយវិការជា អភ័យមុទ្រ និង វរទមុទ្រ។ ចម្លាក់ដែលចាស់ជាងគេរបស់គជលក្ស្មី គឺក្នុង សតវត្សទី២មុនគ្រឹស្តសករាជ ប្រហែលជានៅក្នុងគម្ពីរពុទ្ធសាសនា។*[១] *ចម្លាក់បែបនេះមាននៅលើកាក់ (រូបលេខ១) តំបន់* Azilies *ក្នុងសតវត្សទី១មុនគ្រិស្តរាជ និងក្នុងតំបន់* Kausambi *ក្នុងសតវត្សទី៣នៃគ្រឹស្តសករាជ។*[២] *ក្នុងទេវកថា បង្ហាញថា គជលក្ស្មីគឺជាអវតាមួយរបស់ព្រះនាងលក្ស្មី ហើយជាទូទៅ ដំរី (គជេន្ទ្រ) និងព្រះនាងលក្ស្មីតែងតែស្ថិតក្នុងការបួងសួងដល់ព្រះវិស្ណុ។ ដោយភាពធំរបស់គាត់ ដំរីមានភាពយឺតយ៉ាវក្នុងការផ្តល់ជូនអ្នកដែលគោរពគាត់មិនលឿនដូចព្រះនាងលក្ស្មី។ ព្រះវិស្ណុបានសុំឱ្យព្រះនាងលក្ស្មីចូលរួមជាមួយ ដូចនោះ គជេន្ទ្រអាចផ្តល់នូវការសុំរបស់អ្នកបួងសួងជាមួយគ្នាដែរ។ ពេលនោះព្រះនាងលក្ស្មី បានក្លាយជាទម្រង់ គជលក្ស្មី ហើយទទួលការថ្វាយរបស់ដំរី។*[៣] *គជលក្ស្មីជាពិធីបែបហិណ្ឌូសាសនាមួយដែលគេតែងធ្វើពិធីបួងសួងដល់ព្រះនាងលក្ស្មី ដោយមានគ្រឿងដង្វាយផ្សេងៗ និងភ្លើង (ចង្កៀងភ្លើង) ដើម្បីទទួលបានមកវិញនូវសេចក្តីសុខ សន្តិភាព និងភាពសំបូរនៅក្នុងជិវិត។*

*ជំនឿនិងការគោរពដល់គជលក្ស្មីក្នុងសង្គមខ្មែរនាសម័យបុរាណ ហាក់ដូចជាពុំសូវមានប្រជាប្រិយភាពដូចការគោរពលើទេពផ្សេងទេ ក្នុងសម័យមុនអង្គរ។ ប៉ុន្តែយើងឃើញមានបង្ហាញខ្លះក្នុងចម្លាក់សិល្បៈខ្មែរនាសម័យអង្គរ។ គជលក្ស្មីគឺជាទេវកថាដែលបង្ហាញពីការលាងជម្រះព្រះនាងលក្ស្មីដោយសត្វដំរី២ក្បាល*[៤] *ដែលដំរីទាំង២ក្បាលនេះតំណាង*

---

[១] Coomaraswamy. Ananda (1935:22)

[២] Taylor, Timothy (1992: *266*: 84-89)

[៣] https://www.astroved.com/astropedia/en/goddess/gaja-lakshmi

[៤] Gérard Huet, (2020:281)

ឱ្យទ្រព្យសម្បត្តិរបស់ព្រះកុបេរទាំង២ គឺបទ្មនិធិ (Padmanithi) និងសង្ខនិធិ (Śaṅkhanith i)។ ក្នុងសិល្បៈឥណ្ឌា ចម្លាក់ (ព្រះនាងលក្ស្មី) ជាទូទៅមាននៅតាមហោជាង នៃច្រកចូលរបស់ប្រាង្គសំខាន់ (គភ៌គ្រឹះ)នៃប្រាសាទ (រូបលេខ២២)។

ក្នុងសិល្បៈខ្មែរ ចម្លាក់របស់គជល្ស្មី ជាធម្មតាត្រូវបានបង្ហាញនៅលើផ្តែរទ្វារ (លើកលែងហោជាងនៅប្រាសាទបន្ទាយស្រី) ជាទេពស្រី អង្គុយពែនភ្នែនលើបល្ល័ង្គផ្កាឈូក (បាទសន) ឬធម្មតាមានដៃតែ២ កាន់ផ្កាឈូក ជួនកាលដាក់ផ្ទាល់លើភ្លៅទាំងពីរ ជួនកាលលើកផុតដោយទងផ្កាឈូកស្ថិតនៅលើស្មាទាំងសង្ខាង។ ដំរី២ក្បាលនៅសង្ខាងយកប្រមោយ កាន់ថូទឹកស្រោចទៅលើព្រះនាងលក្ស្មី។ ចម្លាក់ដំបូងដែលមានទម្រង់បែបនេះអាចជាផ្តែរនៅប្រាសាទស្ទូល[៥] (រូបលេខ២៣)[៦] និងអាចស្ថិតក្នុងរចនាបថព្រះគោ ក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស៨៧៧ ដល់ គ.ស៨៨៩) បង្ហាញពីតួអង្គស្រីអង្គុយលើបល្ល័ង្គផ្កាឈូក មានដៃ២ លើកផុតជង្គង់ទាំង២ កាន់ទងផ្កាឈូកគងមកលើស្មា និងមានដំរី២ឈរសង្ខាងលើបល្ល័ង្គផ្កាឈូកដាច់ពីគ្នា បែរយកប្រមោយលើកថូទឹក សំយ៉ុងស្រោចពីលើព្រះកេសទេពលក្ស្មី។ ផ្តែរមួយទៀត នៅប្រាសាទអានន្ត (រូបលេខ២៤) អាចស្ថិតក្នុងរចនាបថព្រះគោ ឬបាខែង ក៏មានបង្ហាញដូចគ្នានូវចម្លាក់គជលក្ស្មី តែប្រមោយដំរីហាក់ដូចពុំមានថូទឹកទេ។

ចម្លាក់មួយទៀត នៅប្រាសាទមេបុណ្យខាងកើត ក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ (គ.ស៩៤៤ដល់៩៦៨) គឺនៅលើផ្តែរទ្វារខាងត្បូងរបស់ប្រាង្គតូចនៅខាងមុខជ្រុងឥសាន្តនៃប្រាង្គកណ្តាល (រូបលេខ២៥) វាខុសបន្តិចពីលក្ខណៈនៃសិល្បៈឥណ្ឌាដែលគេតែងធ្វើចម្លាក់បែបនេះនៅតាមផ្លូវចូលសំខាន់ឆ្ពោះទៅប្រាង្គកណ្តាល។ ចម្លាក់មួយទៀត គឺស្ថិតនៅលើហោជាងខាងកើត (ផ្លូវចូលសំខាន់) នៃគោបុរៈខាងកើតរបស់កំពែងទី២ ប្រាសាទបន្ទាយស្រី (រូបលេខ២៦)។ ផ្តែរមួយនៅសារមន្ទីរវត្តពោធិវាល (បាត់ដំបង) ប្រហែលស្ថិតក្នុងរចនាបថឃ្លាំង (សូរ្យវរ្ម័នទី១ គ.ស១០០២ ដល់ គ.ស១០៥០)បង្ហាញពីចម្លាក់គជលក្ស្មីដែរ (រូបលេខ២៧)។ ចម្លាក់នៅប្រាសាទកំផែងយាយ[៧] (រូបលេខ២៨) ស្ថិតក្នុងរាជ្យព្រះបាទឧទ័យទិត្យវរ្ម័នទី២ (គ.ស១០៥០ដល់១០៦៦) និងប្រាសាទពួយណាយ (រូបលេខ២៩)។[៨]

---

៥ E. Lunet de Lajonquière, (1911:326)

៦ https://collection.efeo.fr/ CAM01388

៧ Michael Freeman, (1996:182)

៨ Vittorio Roveda, (2005:72)

ទាំងនេះជាចម្លាក់ដែលមានលក្ខណៈដូចនឹងទេវកថា និងចម្លាក់បុរាណឥណ្ឌា។ ប៉ុន្តែយើងសង្កេតឃើញមានចម្លាក់នៅលើផ្តែរទ្វារខ្លះទៀតដែលមានទម្រង់ដូចគ្នា ហើយអាចជាចម្លាក់ដែលសិល្បករចង់បង្ហាញអំពីការគោរពលើព្រះនាងលក្ស្មីក្នុងទម្រង់ជាគជលក្ស្មីដែរ។ ចម្លាក់ទាំងនោះមានរូបជាទេពស្រី អង្គុយលើបល្ល័ង្កផ្កាឈូក និងមានដៃ២កាន់ផ្កាឈូកដូចគ្នានឹងចម្លាក់គជលក្ស្មីដែរ ប៉ុន្តែពុំមានវត្តមានសត្វដំរីនៅសង្ខាងឡើយ។ នេះអាចជាទម្រង់មួយទៀត ដូចគ្នាទៅនៅការបង្ហាញចម្លាក់ព្រះឥន្ទ្រជិះលើដំរីក្បាល៣ដែរ។[៩] ផ្តែរមួយអាចស្ថិតនៅក្នុងរចនាបថសំបូរព្រៃគុក (រូបលេខ១០) ជាផ្តែរបង្ហាញពីផ្ទៃរឿង មានទេពស្រីអង្គុយពែនភ្នែនលើបល្ល័ង្កផ្កាឈូក ដៃទាំង២កាន់ផ្កាឈូក២ទង ស្ថិតក្នុងរង្វង់ក្បាច់មេដាយ៉ុង និងទេពផ្សេងទៀតនៅសង្ខាង ប្រណមចំពោះព្រះនាង។ នៅចុងម្ខាងៗនៃផ្តែរជាចម្លាក់មករបែរចូលក្នុង មានប្រមោយដូចដំរី អាចជានិមិត្តរូបជំនួសឱ្យសត្វដំរី។ លក្ខណៈបែបនេះអាចវិវត្តន៍រហូតមកដល់រចនាបថគូលែន និងព្រះគោ នាដើមសម័យអង្គរ។ ឧទាហរណ៍ ផ្តែរនៅប្រាសាទដូនមា បង្ហាញពីចម្លាក់ទេពស្រីអង្គុយនៅចំកណ្តាលផ្តែរ លើបល្ល័ង្កផ្កាឈូកនៅលើក្បាលកាលា មានដៃ២កាន់ទងផ្កាឈូកដែលក្រពុំផ្កាទាំង២នោះគងមកលើស្មា (រូបលេខ១១)។ ចម្លាក់មានទម្រង់បែបនេះមានវត្តមានច្រើននៅបាគង ក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស៨៧៧ ដល់៨៨៩) ដែលចម្លាក់បែបនេះមានបង្ហាញនៅលើផ្តែរទ្វារដែលឧទ្ទិសដល់ទេពស្រី ពិសេសនៅតាមប្រាង្គរណបជ្រុងខាងត្បូង (រូបលេខ១២-១៣)។ លើសពីនេះផ្តែររបស់ប្រាង្គខាងត្បូងរបស់ប្រាសាទនាងខ្មៅ (តាកែវ) ស្ថិតក្នុងរចនាបថព្រះគោ[១០] ក៏បង្ហាញពីទេពស្រីអង្គុយពែនភ្នែនក្នុងក្បាច់កម្រងផ្កាលើក្បាលកាលា ដៃ២កាន់ផ្កាឈូក២ទង (រូបលេខ១៤)។ ក្រៅពីចម្លាក់លើផ្តែរ និងហោជាងទម្រង់រឿង គជលក្ស្មី អាចត្រូវបានសិល្បៈកររចង់បង្ហាញនៅតាមស៊ុំទ្វារបញ្ឆោតរបស់ប្រាង្គមួយចំនួនដែរ ឧទាហរណ៍នៅប្រាសាទគងដំរី រលួស (រូបលេខ១៥)។ ចម្លាក់លើផ្តែរខាងកើតរបស់ប្រាង្គខាងជើងប្រាសាទក្រវ៉ាន់ក៏បង្ហាញពីទេពមួយអង្គុយលើផ្កាឈូក និងមានដៃ២កាន់ទងផ្កា (រូបលេខ១៦) អាចជាព្រះនាងលក្ស្មី ព្រោះប្រាង្គ និងចម្លាក់លើជញ្ជាំងខាងក្នុងបង្ហាញថា ប្រាង្គនេះជាទីសក្ការៈដល់ព្រះនាងលក្ស្មី។

ក្រៅពីចម្លាក់ទាំងនេះ យើងឃើញមានក្នុងសិលាចារឹកមួយចំនួនដែលនិយាយគោរពដល់ព្រះនាងលក្ស្មី តែមិនបានបញ្ជាក់ថាជា គជលក្ស្មីទេ។ ឧទាហរណ៍ សិលាចារឹក

---

[៩] សុខ កែវ សុវណ្ណារ៉ា, (២០២០)

[១០] សុខ កែវ សុវណ្ណារ៉ា (២០២០: ១៣-២២)

នៅលើថ្មខាងមុខប្រាង្គខាងជើងរបស់ប្រាសាទព្រះឥន្ទ្រកោសីយ (K.263)[១១] និយាយរំលឹកអំពីការគោរព និងបូជាដល់ព្រះនាងលក្ស្មី ( នា វ្រះ កម្រតេង អញ ភគវតីយ) ដែលជាទេពត្រូវបានដម្កល់ក្នុងប្រាង្គខាងជើងនោះ។ សិលាចារឹកមួយទៀតនៅលើស៊ុំទ្វារខាងត្បូងរបស់ប្រាង្គខាងជើង (ប្រាង្គមានចម្លាក់ព្រះនាងលក្ស្មីលើផ្តែរ និងជញ្ជាំងខាងក្នុង) ប្រាសាទក្រវ៉ាន់ (K.271)[១២] ក៏និយាយអំពីការឧទ្ទិសដល់ព្រះនាងលក្ស្មីដែរ ( *៨៤៣សក នុ កំស្តេង អញ ស្រីមហីធរវម្ម៌ និវេទន វ្នក . . . ភគវតី កម្រតេង អញ វ្រះ ស្រីយ*)។

សរុបមកវិញ យើងឃើញថា គជលក្ស្មីជាជំនឿមួយរបស់ជនជាតិឥណ្ឌាតាំងពីបុរាណរហូតមកលប់បច្ចុប្បន្ន គឺគេនៅតែគោរព និងធ្វើពិធីនេះគ្រប់ពេលវេលា។ ចំពោះពិធីបួងសួងឧទ្ទិសដល់ព្រះនាងក្នុងទិដ្ឋភាពជាគជលក្ស្មីក្នុងសង្គមខ្មែរបុរាណ គឺមានលក្ខណៈជាការគោរពបូជាបែបបុគ្គល មិនមានភាពទូលាយឬជាសកលដូចការគោរពលើទេពដទៃ (ព្រះសិវៈ វិស្ណុ ឧមា ទុគ៌ា ...ជាដើម) ទេ។ ការគោរពលើគជលក្ស្មីបង្ហាញបានត្រឹមចម្លាក់ក្រឡោតទាប តូចៗនៅលើផ្តែរ ហោជាង និងស៊ុំទ្វារ ពុំមានជាបដិមាឡើយ។ វត្តមានដំបូងអាចបង្ហាញតាមចម្លាក់ផ្តែរក្នុងរចនាបថសំបូរព្រៃគុក បន្តមកគូលែន រហូតដល់បាភួន។ តាមចម្លាក់ទាំងនេះ យើងអាចឃើញមានទិដ្ឋភាព២ ដែលតំណាងឱ្យគជលក្ស្មីក្នុងសិល្បៈខ្មែរ គឺ៖

១.ទម្រង់ជាទេពស្រីអង្គុយលើផ្កាឈូក មានដៃ២កាន់ទងផ្កាឈូក២ គងមកលើស្មា ពុំមានដំរីសង្ខាងទេ។ ចម្លាក់បែបនេះលេចឡើងក្នុងរចនាបថសំបូរព្រៃគុក គូលែន ព្រះគោ និងកោះកេរ។

២. ទម្រង់ជាទេពស្រីអង្គុយលើផ្កាឈូក មានដៃ២កាន់ទងផ្កាឈូក២ គងមកលើស្មា មានដំរីសង្ខាង ប្រមោយកាន់ថូ ស្រោចលើព្រះកេសព្រះនាងលក្ស្មី។ ចម្លាក់បែបនេះលេចឡើងក្នុងរចនាបថព្រះគោ បាខែង កោះកេរ ប្រែរូប បន្ទាយស្រី ឃ្លាំង និងបាភួន( ? )។

---

[១១] G. Cœdès, (1952:127, D:6)

[១២] G. Cœdès, (1952:75)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ១៖ កាក់រូបគជលក្ស្មី (wikipedia.org)



រូបលេខ២៖ ចម្លាក់គជលក្ស្មីនៅប្រាសាទកៃលស (wikipedia.org)



រូបលេខ៣៖ គជលក្ស្មីផ្តែរប្រាសាទស្ពូល (EFEO)



រូបលេខ៤៖ គជលក្ស្មីផ្តែរប្រាសាទអនន្ត (EFEO)



រូបលេខ៥៖ គជលក្ស្មីផ្តែរប្រាសាទមេបុណ្យខាងកើត



រូបលេខ៦៖ គជលក្ស្មីផ្តែរប្រាសាទបន្ទាយស្រី



រូបលេខ៧៖ គជលក្ស្មីផ្តែរវត្តពោធិវាល





រូបលេខ៨-៩៖ គជលក្ស្មី ផ្តែរប្រាសាទកំពែងយាយ និងពួយណយ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា


រូបលេខ១០៖ ផ្តែរនៅសំបូរព្រៃគុក (EFEO)


រូបលេខ១១៖ ផ្តែរនៅប្រាសាទដូនមា (EFEO)


រូបលេខ១២៖ ផ្តែរនៅប្រាសាទបាគង (EFEO)


រូបលេខ១៣៖ ផ្តែរនៅប្រាសាទបាគង (EFEO)


រូបលេខ១៤៖ ផ្តែរនៅប្រាសាទនាងខ្មៅ (តាកែវ)


រូបលេខ១៥៖ ផ្តែរនៅប្រាសាទគងដំរី


រូបលេខ១៦៖ ផ្តែរនៅប្រាសាទក្រវ៉ាន់ (EFEO)

## ឯកសារយោង

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

សុខ កែវ សុវណ្ណារ៉ា
២០២០. *ដំរីក្បាលបាញ់ទឹក*, ក្នុងគេហទំព័រ ASM Khmer Civilization, ភ្នំពេញ។
សុខ កែវ សុវណ្ណារ៉ា
២០២០. *ទស្សនៈថ្មីលើប្រាសាទព្រះវិស្ណុ*, ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា, លេខ២៣, សៀមរាប។

Coomaraswamy. Ananda

1935. *Elements of Buddhist Iconography*, Harvard University Press.

E. Lunet de Lajonquière

1911. *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris.

Gérard Huet

2020. *Dictoinnaire Sanskrit-Fraçais*.

G. Cœdès

1952. *Inscription du Cambodge*, Volume IV, Paris.

https://collection.efeo.fr/ CAM01388

https://www.astroved.com/astropedia/en/goddess/gaja-lakshmi

Michael Freeman

1996. *A Guide to Khmer Temples in Thailand and Laos*, River Books, Thailand.

Taylor, Timothy

1992. *The Gundestrup cauldron*", Scientific American.

Vittorio Roveda

2005. *Images of the Gods*, River Books, Thailand.